00970785

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 23 / 01 / 2014
ម៉ោង (Time/Heure) : 15:15
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Sann Rada

E2/24/1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

## អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៤

**ជូនចំពោះ:** គ្រប់ភាគីទាំងអស់នៃសំណុំរឿង ០០២

**ពី:** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន:** លោក/លោកស្រីចៅក្រម និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ:** ការបន្តសិទ្ធិដើមបណ្តឹងរដ្ឋប្បវេណី ពីឈ្មោះ ម៉ៅ សុន ដែលបានទទួលមរណៈភាព ក្នុងសំណុំរឿង ០០២

១. នៅថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៣ លោកស្រី ផេត វណ្ណលី មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានដាក់សំណើមួយ (ឯកសារ E2/24) ដោយបានជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូងថា កូនក្តីរបស់គាត់លោកស្រី ម៉ៅ សុន (D22/1224) បានទទួលមរណភាព។ នៅក្នុងសំណើនោះ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូងថា ប្តីរបស់កូនក្តីគាត់នឹងបន្តសិទ្ធិបណ្តឹងរដ្ឋប្បវេណី។ ភ្ជាប់ជាមួយសំណើនោះ មានសេចក្តីថ្លែងការណ៍សិទ្ធិវន្តរបស់លោក គីម អ៊ុក សំបុត្រមរណភាពរបស់លោកស្រី ម៉ៅ សុន ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៣ និងអត្តសញ្ញាណប័ណ្ណរបស់លោក គីម អ៊ុក ។

២. ក្រោយពីបានទទួលសំណើ និងឯកសារដែលមានភ្ជាប់មកជាមួយ អង្គជំនុំជម្រះសាលាដំបូង កត់សម្គាល់ឃើញថា ដើមបណ្តឹងរដ្ឋប្បវេណី ម៉ៅ សុន ត្រូវបានទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសំណុំរឿង ០០២ ហេតុដូច្នេះប្តីរបស់លោកស្រី ម៉ៅ សុន គឺជាសិទ្ធិវ័ន្តរបស់លោកស្រី។

៣. យោងតាមសម្អាងហេតុ ដែលបានបញ្ជាក់ក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង លើសំណើសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលបានទទួលមរណភាព E2/5/3 នៅក្នុងសំណុំរឿង ០០១ អង្គជំនុំជម្រះសាលាដំបូងសម្រេចថា លោក គីម អ៊ុក ដែលជាប្តីរបស់ដើមបណ្តឹងរដ្ឋប្បវេណី ម៉ៅ សុន អាចបន្តសិទ្ធិបណ្តឹងរដ្ឋប្បវេណីក្នុងនាមជាសិទ្ធិវ័ន្តក្នុងសំណុំរឿង ០០២ បាន។